CITY OF LONG BEACH

# PRESS RELEASE

**សេចក្តីប្រកាសព័ត៌មាន**

ថ្ងៃទី 11 ខែកុម្ភៈ ឆ្នាំ 2021

ទំនាក់ទំនង ៖ Jane Grobaty, មន្ត្រីព័ត៌មានសហគមន៍, ឧទ្យានឡុងប៊ិច, ការកំសាន្ត និងកំពង់ផែកំសាន្ត, 562.570.3233, Jane.Grobaty@longbeach.gov

សម្រាប់ការផ្សព្វផ្សាយភ្លាមៗ

# សេវាថែទាំសត្វឡុងប៊ិច សម្ពោធបើកដំណើរការកិច្ចខិតខំប្រឹងប្រែងផ្សព្វផ្សាយ សម្រាប់សំណើផែនការយុទ្ធសាស្ត្រ

*ស្វែងរក ធាតុចូលពីសហគមន៍*

ឡុងប៊ិច, CA - សាលាក្រុងឡុងប៊ិច ការិយាល័យសេវាថែទាំសត្វ (LBACS) នៅនាយកដ្ឋានឧទ្យានការកំសាន្ត និងសមុទ្រ (PRM) នឹងសម្ពោធបើកដំណើរការកិច្ចខិតខំប្រឹងប្រែងផ្សព្វផ្សាយបន្ថែមទៀត សម្រាប់សំណើផែនការយុទ្ធសាស្ត្រ ដើម្បីស្វែងរកធាតុចូលបន្ថែមទៀត ពីសហគមន៍តាមរយៈការស្ទង់មតិ តាមអ៊ីនធឺណែត និងវេទិកាសាធារណៈ តាមអ៊ីនធឺណែត ។

សេចក្តីព្រាងផែនការយុទ្ធសាស្ត្រ ត្រូវបានរៀបចំឡើង តាមរយៈសកម្មភាពផ្សព្វផ្សាយ យ៉ាងសកម្ម ជាមួយក្រុមការងារចក្ខុវិស័យថែទាំសត្វ ។ ផែនការនោះត្រូវបានប្រកាស ជាសាធារណៈ ហើយត្រូវបានរៀបចំជារបៀបវារៈ នៅថ្ងៃទី 8 ខែធ្នូ ឆ្នាំ 2020 សម្រាប់កិច្ចប្រជុំក្រុមប្រឹក្សាក្រុងឡុងប៊ិច ។ នៅក្នុងកិច្ចប្រជុំនោះ មានអនុញ្ញាតឱ្យសាធារណជន បញ្ចេញមតិយោបល់ ហើយក្រុមប្រឹក្សាក្រុងបានស្នើសុំបន្ថែមពេលវេលា មុនពេលធ្វើការអនុម័ត ដើម្បីអនុញ្ញាតឱ្យមាន វគ្គប្រមូលធាតុចូលបន្ថែមទៀត ពីសហគមន៍ ។

ចៅហ្វាយក្រុង រ៉ូប៊ើត ហ្គាសៀ (Robert Garcia) បានបញ្ជាក់ថា «ការសម្ពោធបើកដំណើរការគំនិតផ្តួចផ្តើម ដើម្បីផ្តល់ធាតុចូល បន្ថែមទៀត ពីសហគមន៍របស់យើង ចំពោះសេចក្តីព្រាងផែនការនេះ នឹងជួយយើងឱ្យអាចបង្កើតបាន កម្មវិធីសុខមាលភាពសត្វ បានច្បាស់លាស់ ប្រកបដោយជោគជ័យ នៅឡុងប៊ិចយើងនេះ» ។

សមាជិកសហគមន៍ ត្រូវបានអញ្ជើញឱ្យធ្វើការពិនិត្យឡើងវិញ លើ សំណើផែនការយុទ្ធសាស្ត្រ និងបំពេញ កម្រងសំណួរស្ទង់មតិ ខ្លីមួយ ។ ពួកគេក៏អាចចែករំលែក ព័ត៌មានត្រឡប់ បានផងដែរ ដោយត្រូវចូលរួម វេទិកាសាធារណៈ តាមអ៊ីនធឺណែត ឬដោយអ៊ីមែល ទៅ LBACS តាមរយៈ ACSStrategicPlan@longbeach.gov ។

វេទិកាសាធារណៈតាមអ៊ីនធឺណែត នឹងប្រព្រឹត្តទៅ នៅកាលបរិច្ឆេទ ដូចខាងក្រោមនេះ ។ ព័ត៌មានលំអិត អំពីរបៀបចូលរួម អាចករបាននៅលើ គេហទំព័រសេវាថែទាំងសត្វ និងដោយចុចលើ រូបសញ្ញា «វេទិកាសាធារណៈ ស្តីពីផែនការយុទ្ធសាស្ត្រ» ។

- ថ្ងៃសៅរ៍ ទី 13 ខែកុម្ភៈ ពីម៉ោង 2 រសៀល ដល់ម៉ោង 4 ល្ងាច
- ថ្ងៃពុធ ទី 17 ខែកុម្ភៈ ពីម៉ោង 6:30 ដល់ម៉ោង 8:30 យប់

CITY OF LONG BEACH

# PRESS RELEASE

កិច្ចខិតខំប្រឹងប្រែង ក្នុងការរៀបចំបង្កើតផែនការយុទ្ធសាស្ត្រនេះ ពីដំបូងឡើយ បានចាប់ផ្តើម នៅឆ្នាំ 2017 នៅពេលសាលាក្រុងឡុងប៊ិច បានរៀបចំចុះបញ្ជីជំនាញ របស់យុទ្ធសាស្ត្រជម្រក នៃក្រុមហ៊ុនប្រឹក្សាផ្នែកគ្រប់គ្រង JVR ដើម្បីធ្វើសវនកម្មប្រតិបត្តិការរបស់ទីផ្តល់ជម្រក ដែលបានកំណត់រក ចំណុចសំខាន់ៗ សម្រាប់កែលំអឡើងវិញ ។ សេចក្តីព្រាងផែនការមួយ ត្រូវបានរៀបរាងឡើង នៅឆ្នាំ 2019 ដោយបុគ្គលិកសាលាក្រុង សហការជាមួយ ក្រុមការងារចក្ខុវិស័យថែទាំសត្វ របស់ចៅហ្វាយក្រុង និងត្រូវបានសម្របសម្រួល ដោយក្រុមហ៊ុនធ្វើការលើការផ្លាស់ប្តូរ និងយុទ្ធសាស្ត្រគ្រឹះស្ថានមួយ ។

នៅខែឧសភា ឆ្នាំ 2019 ក្រុមប្រឹក្សាក្រុងឡុងប៊ិច បានអនុម័ត ជាឯកឆន្ទ លើម៉ូដែលក្តីមេត្តាសង្គ្រោះ សម្រាប់ LBACS ដែលធានាឱ្យ សត្វដែលមានសុខភាពល្អ និងអាចយកមកព្យាបាលបានទាំងអស់ នៅតាមទីផ្តល់ជម្រក ត្រូវបានសង្គ្រោះ ។ សមាសភាគសំខាន់ៗ របស់គំរូក្តីមេត្តាសង្គ្រោះ មានរំលេច នៅក្នុងសំណើផែនការនោះ ។

ប្រ៊ែន ឌេននីស (Brent Dennis) ប្រធានឧទ្យាន ការកំសាន្ត និងសមុទ្រ បានគូសបញ្ជាក់ថា «សំណើផែនការយុទ្ធសាស្ត្រ ដ៏ខ្លាំងក្លានេះ គឺជា ផែនការដំបូងគេ សម្រាប់ LBACS» «យើងប្តេជ្ញាអនុវត្តគំនិតផ្តួចផ្តើម ដែលរួមបញ្ចូលម៉ូដែលក្តីមេត្តាសង្គ្រោះ ហើយធាតុចូលពីសហគមន៍របស់យើង មានសារៈសំខាន់ណាស់ ចំពោះជោគជ័យរបស់ផែនការនេះ ។»

ផែនការនេះនឹងប្រើ រយៈពេលបួនឆ្នាំ ចាប់ពីឆ្នាំ 2021 ដល់ឆ្នាំ 2024 ហើយនឹងដើរតួជាមគ្គុទេសក៍សម្រាប់ សេចក្តីសម្រេច ផ្នែកប្រតិបត្តិការ LBACS, ផ្នែកជ្រើសរើសបុគ្គលិក និងផ្នែកថវិកា ។

**អំពីសាលាក្រុងឡុងប៊ិច**

មានប្រជាជនប្រមាណ 480,000 នាក់ សាលាក្រុងឡុងប៊ិច ដែលបានទទួលបានពានរង្វាន់ និងច្នៃប្រឌិតថ្មីជាច្រើន បានផ្តល់ជូននូវភាពសំបូរបែបនៃពិភពលោកនៃទីក្រុងធំមួយ ខណៈពេលដែលរក្សាបាននូវលក្ខណៈភាពជាបុគ្គល និងមានចម្រុះដោយភូមិស្ថានផ្សេងៗគ្នាផ្តុំគ្នានៅតាមបណ្តោយឆ្នេរសមុទ្រ California។ ក្នុងនាមជាទីក្រុងដែលផ្តល់សេវាកម្មពេញលេញ, ទីក្រុងឡុងប៊ិចជាទីតាំងនៃសារមន្ទីរ និងមហោស្រពជាច្រើន ដូចជា Queen Mary, Aquarium of the Pacific, និងមានកន្លែងជាច្រើនទៀត មណ្ឌលសាលារៀនដែលត្រូវបានគេវាយតម្លៃខ្ពស់, អាកាសយានដ្ឋានឡុងប៊ិច និងកំពង់ផែឡុងប៊ិច។ មន្ទីរសាលាក្រុង បានឈ្នះពានរង្វាន់ជាច្រើន ផ្សេងទៀតដូចជាសុខភាព សួនឧទ្យាន កំពង់ផែកំសាន្ត និងសេវាកម្មអភិវឌ្ឍន៍ និងផ្សេងៗទៀត។ ទីក្រុងក៏មានសាកលវិទ្យាល័យ និងមហាវិទ្យាល័យដែលត្រូវបានគេវាយតម្លៃខ្ពស់, មានកន្លែងកសិដ្ឋានចិញ្ចឹមសត្វជាប្រវត្តិសាស្ត្រពីរកន្លែង, មន្ទីរពេទ្យប្រាំ កន្លែង, ទីវាលហ្វឹកហាត់វាយកូនហ្គោលប្រាំកន្លែង, សួនច្បារ 170, ឆ្នេរសមុទ្ររាប់សិបម៉ាយល៍, កំពង់ផែសម្រាប់លំហែកំសាន្តជាច្រើនកន្លែង, គន្លងផ្លូវជិះកង់ និងកម្មវិធីចែកចាយកង់។

សម្រាប់ព័ត៌មានបន្ថែមទៀត អំពីទីក្រុងឡុងប៊ិច សូមចូលទៅ http://longbeach.gov/ ។ សូមតាមយើងខ្ញុំ នៅលើបណ្តាញសង្គមដើម្បីទទួលបានព័ត៌មានចុងក្រោយបំផុតនានា ៖ Facebook, Twitter, Instagram vនិង YouTube ។

**អំពីនាយកដ្ឋានឧទ្យាន ការកំសាន្ត និងសមុទ្រ**

នាយកដ្ឋានឧទ្យាន ការកំសាន្ត និងសមុទ្រ (PRM) ត្រូវបានទទួលស្គាល់ ដោយសារភាពល្អឥតខ្ចោះ ក្នុងប្រតិបត្តិ និងកម្មវិធីគ្រប់គ្រង ដោយទទួលបានជ័យលាភីមេដាយមាស ពីសមាគមឧទ្យានជាតិ និងការកំសាន្ត ចំនួនបួនដង ។ PRM ផ្តល់នូវកម្មវិធីកម្សាន្តនិងសេវាកម្មដល់ពលរដ្ឋ និងភ្ញៀវទេសចរដែលធ្វើអោយប្រសើរឡើងនូវគុណភាពជីវិតនៅឡុងប៊ិច។ PRM ថែរក្សាឧទ្យានចំនួន 171 កន្លែងដែលមានមជ្ឈមណ្ឌលសហគមន៍ចំនួន 26 កន្លែង, 320 អ៊ែរនៃទីធ្លាទូលាយ និងឆ្នេរសមុទ្រ 6,1 ម៉ាយល៍ អនុវត្តផែនការបើកលំហនៃទីក្រុងផ្តល់នូវការកម្សាន្តដើម្បីបំពេញតំរូវការសហគមន៍ផ្សេងៗគ្នា ថែរក្សាកំពង់ផែកំសាន្តសាធារណៈ និងផ្តល់នូវសុវត្ថិភាព និងការប្រព្រឹត្តចំពោះសត្វដល់សាធារណៈ។

សម្រាប់ព័ត៌មានបន្ថែមទៀត អំពីសេវាថែទាំសត្វ ឡុងប៊ិច សូមចូលទៅ http://www.longbeach.gov/acs ។ តាមដានពួកយើងនៅលើសង្គមដើម្បីទទួលបានព័ត៌មានថ្មីៗ Facebook, Twitter និង Instagram ។

# # #